**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ០២៧ សរណន កសក

រដ្ឋបាលជលផល
មកដល់ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៩
លេខៈ ១៣៧ ម៉ោង ១១:០០

# សារាចរណែនាំ
## ស្ដីពី
## វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ដោយប្រើឧបករណ៍នេសាទលបកន្ទុយកណ្ដុរ ឬលបពោះវៀនជ្រូក ឬលបប្រើស១០០

កន្លងមកថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានពិនិត្យឃើញថា មានសកម្មភាពធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទលបកន្ទុយកណ្ដុរ ឬលបពោះវៀនជ្រូក ឬលបប្រើស១០០ បាននិងកំពុងកើតមានឡើងនៅក្នុងដែននេសាទគួរឱ្យព្រួយបារម្ភ ដោយហេតុថា ឧបករណ៍នេសាទនេះទើបបានបង្កើតថ្មី របៀបនេសាទថ្មី និងជាឧបករណ៍នេសាទដែលពុំមានចែងនៅក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទេ។ កន្លងមក ការទប់ស្កាត់ និងបង្ក្រាបបទល្មើសដោយប្រើឧបករណ៍នេសាទលបកន្ទុយកណ្ដុរ ឬលបពោះវៀនជ្រូក ឬលបប្រើស១០០ របស់សមត្ថកិច្ចជលផលពុំទាន់ទទួលបានប្រសិទ្ធភាពនៅឡើយ។

ដូចនេះ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលខាងលើទទួលបានប្រសិទ្ធភាព និងធានាបាននិរន្តភាពធនធានជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់សមត្ថកិច្ចគ្រប់ថ្នាក់ចាត់វិធានការឱ្យបានម៉ឺងម៉ាត់ដូចខាងក្រោម៖

### ១-វិធានការអប់រំនិងផ្សព្វផ្សាយ

សមត្ថកិច្ចជលផលគ្រប់ថ្នាក់ ត្រូវធ្វើការផ្សព្វផ្សាយច្បាប់ស្ដីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ជាពិសេសប្រកាសស្ដីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទនៅក្នុងដែននេសាទ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនដល់ប្រជាពលរដ្ឋ អ្នកនេសាទ វារីវប្បករ អាជ្ញាធរមូលដ្ឋាន សហគមន៍នេសាទ និងអ្នកពាក់ព័ន្ធដទៃទៀតឱ្យបានទូលំទូលាយ និងជ្រួតជ្រាបតាមគ្រប់មធ្យោបាយ ដើម្បីចូលរួមទប់ស្កាត់ និងបង្ក្រាបការធ្វើនេសាទដោយប្រើឧបករណ៍នេសាទលបកន្ទុយកណ្ដុរ ឬលបពោះវៀនជ្រូក ឬលបប្រើស១០០ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីធានានិរន្តរភាពធនធានជលផលសម្រាប់កូនចៅជំនាន់ក្រោយៗ។ ក្នុងដំណាក់កាលនេះផងដែរ សមត្ថកិច្ចជលផលគ្រប់ថ្នាក់ ត្រូវបំផុសចលនាប្រមូលឧបករណ៍នេសាទលបកន្ទុយកណ្ដុរ ឬលបពោះវៀនជ្រូក ឬលបប្រើស១០០យកមកធ្វើការបំផ្លាញចោលនៅទីសាធារណៈ និងបំផុសចលនាប្រជាពលរដ្ឋនិងអ្នកនេសាទឱ្យមកធ្វើនេសាទដោយឧបករណ៍នេសាទស្របច្បាប់វិញ។

### ២-វិធានការអនុវត្តច្បាប់

រដ្ឋបាលជលផលមានសមត្ថកិច្ចគ្រប់ថ្នាក់ ត្រូវសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចពាក់ព័ន្ធដែលស្ថិតក្រោមការដឹកនាំសម្របសម្រួលរបស់គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ធ្វើការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលនេសាទដោយប្រើឧបករណ៍នេសាទលបកន្ទុយកណ្ដុរ ឬលបពោះវៀនជ្រូក ឬលបប្រើស១០០



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Ch...
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

Scanned with CamScanner

ឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមសារាចរណែនាំលេខ០៥ សរណន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិនិងអនុវត្តចំណាត់ការដូចខាងក្រោម៖

ក្នុងពេលចុះប្រតិបត្តិការត្រួតពិនិត្យបទល្មើសជលផលជួបប្រទះបទល្មើសជាក់ស្តែងដោយប្រើឧបករណ៍លបកន្ទុយកណ្តុរឬលបពោះវៀនជ្រូក ឬលបប្រើស១០០ មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចត្រូវចាត់វិធានការរុះរើដកហូតវត្ថុតាងនិងបំផ្លាញចោល ឬចាប់ខ្លួនជនប្រព្រឹត្តបទល្មើសជាក់ស្តែងដោយធ្វើកំណត់ហេតុស្របតាមប្រកាសរួមលេខ១១៥ កយ.កសក. ប្រក/១១/៥៧០ កសក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពី"ទម្រង់បែបបទនៃកំណត់ហេតុបទល្មើសជលផល" របស់ ក្រសួងយុត្តិធម៌និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ចំពោះការកសាងសំណុំរឿងបទល្មើសជលផលប្រើឧបករណ៍នេសាទលបកន្ទុយកណ្តុរឬលបពោះវៀនជ្រូក ឬលបប្រើស១០០ មន្ត្រីនគរបាលយុត្តិធម៌ជលផលមានសមត្ថកិច្ចត្រូវចោទប្រកាន់បទល្មើសតាមមាត្រា២០ ចំណុច១៤ នៃច្បាប់ស្តីពីជលផលដែលត្រូវផ្តន្ទាទោសតាមមាត្រា៩៨ ចំណុច៦ នៃច្បាប់ស្តីពីជលផល។

ក្រោយពីទទួលបានសារាចរណែនាំនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា សមត្ថកិច្ចរដ្ឋបាលជលផល មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តនិងសមត្ថកិច្ចពាក់ព័ន្ធជាពិសេសគណៈបញ្ជាការឯកភាព រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងអនុវត្តតាមខ្លឹមសារសារាចរណែនាំនេះយ៉ាងម៉ឺងម៉ាត់និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ.អង្គារ.១០.កើត......ខែ.[illegible]......ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......១៥..........ខែ..[illegible]......ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



Scanned with CamScanner